**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការក្រុងព្រះសីហនុ**

<u>សំណុំរឿងព្រហ្មទណ្ឌ</u>

លេខ ២៩៧ ចុះថ្ងៃទី ០៤

ខែ ធ្នូ ឆ្នាំ ២០០៣

<u>សាលក្រម</u>

លេខ ៣៦ ចុះថ្ងៃទី ០២

ខែ មិថុនា ឆ្នាំ ២០០៤

**គានខាមប្រជារាស្ត្រខ្មែរ**

**តុលាការក្រុងព្រះសីហនុ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅនេះ :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងព្រះសីហនុ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ក្រឡាបញ្ជីតុលាការក្រុងព្រះសីហនុ

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៩៧ ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៣ ដែលមានជនជាប់ចោទឈ្មោះ **ស ឌ** ហៅ **ជ** ភេទប្រុស អាយុ ៣៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិភ្នំដិន ឃុំភ្នំដិន ស្រុកគិរីវង្ស ខេត្តតាកែវ ទីលំនៅសព្វថ្ងៃក្រុម ៤ ភូមិ ៤ សង្កាត់អូរត្រេះ ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ របររកស៊ីដុតធ្យូង ឪពុកឈ្មោះ **ឌ ញ** (ស) ម្តាយឈ្មោះ **ស គ** (រ) ប្រពន្ធឈ្មោះ **ស ញ** មានកូន ០៤នាក់ ទោសពីមុន *គ្មាន* ។ ចាប់ខ្លួន ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៣ ឃុំខ្លួនថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៣ ។

ត្រូវចោទពីបទ "**បង្ករបួសស្នាមដោយចេតនា**" ប្រព្រឹត្តនៅភូមិ ៤ សង្កាត់អូរត្រេះ ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៣ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ឈ្មោះ **ឧ សម** ហៅ **ញ** មានទីលំនៅភូមិ ៤ សង្កាត់អូរត្រេះ ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ជាដើមបណ្តឹងរដ្ឋប្បវេណី ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១៥៥ ដ.ស.ព ០៤ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៤ របស់ព្រះរាជអាជ្ញាអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ៤២០ ត.ព ០៤ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៤ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

**<u>ដំណើររឿងមានដូចតទៅ</u>** :

កាលពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៣ វេលាម៉ោង១៨ និង ៣០នាទី ឈ្មោះ

*សាលក្រមនេះបានចូលជាស្ថាពរហើយ ។*

*ក្រុងព្រះសីហនុ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤*

**ក្រឡាបញ្ជី** [redacted]

CamScanner

**ឧ សម** ហៅ ញ បានលីកាំបិតដើររ៉េរ៉ៃនៅមុខផ្ទះគាត់ ស្ថិតនៅក្រុម ៤ ភូមិ ៤ សង្កាត់អូរត្រេះ ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ បានស្រែកឡូឡាដោយមូលហេតុខឹងកូនប្រុសស្រីរបស់គាត់ឈ្មោះ **ឧ ឌ** ព្រមទាំងនិយាយប្រមាថមើលងាយរកកាប់កូនគាត់សម្លាប់ចោល និង ចាប់រំលោភលើកូនប្រសាររបស់គាត់ទៀតផង ។ ពេលនោះប្រពន្ធរបស់ឈ្មោះ **ស ឌ** ឈ្មោះ **ប ញ** ឮសូរឈ្មោះ **ឧ សម** និយាយដូច្នេះដោយប៉ះពាល់យ៉ាងខ្លាំងដល់ប្អូនថ្លៃក៏បាននាំប្តីឈ្មោះ **ស ឌ** ទៅផ្ទះឈ្មោះ **ឧ សម** ហើយបានសួរទៅ **ឧ សម** ថា : ពូឯងចង់កាប់កូនពូឯងទៅកុំប៉ះពាល់ប្អូនថ្លៃខ្លួន ពេលនោះ **ឧ សម** ខឹងខ្លាំងណាស់ ក៏ស្ទុះទៅរកកាប់ឈ្មោះ **ស ឌ** ប៉ុន្តែត្រូវប្រពន្ធ **ស ឌ** ឃាត់ បន្ទាប់ មកឈ្មោះ **ឧ សម** បានបោចសក់ឈ្មោះ **ប ញ** ផ្តួលទៅដី ដោយឃើញប្រពន្ធរបស់ខ្លួនត្រូវឈ្មោះ **ឧ សម** ធ្វើដូច្នោះ ឈ្មោះ **ស ឌ** ក៏ស្ទុះទៅជួយ ប៉ុន្តែត្រូវឈ្មោះ **ឧ សម** កាប់មួយកាំបិតចំស្មាស្តាំ ពេលនោះអ្នកជិតខាងចូលឃាត់ ។ ដោយឈ្មោះ **ស ឌ** ខឹងក៏ទៅផ្ទះយកកាំបិតផ្គាក់របស់ខ្លួនមកសងសឹក ពេលដើរមកដល់ចំណុចស្មៅដុះស៊ុបទ្រុបឈ្មោះ **ឧ សម** បានលាក់ខ្លួននៅទីនោះបានស្ទាក់វ៉ៃឈ្មោះ **ស ឌ** មួយដំបងត្រូវចំគុម្ពត្រចៀកបណ្តាលអោយដួលទៅលើដី បន្ទាប់មក **ស ឌ** បានស្រវ៉ាកាំបិតកាប់ទៅលើឈ្មោះ **ឧ សម** វិញត្រូវចំជើងឆ្វេងបណ្តាលអោយរងរបួសជាទម្ងន់ ដោយឃើញដូច្នោះប្រពន្ធរបស់ឈ្មោះ **ឧ សម** បានគប់ឈ្មោះ **ស ឌ** មួយកាំបិតប៉ុងតោចំខាងក្រោមដៃស្តាំ បន្ទាប់មកអ្នកជិតខាងក៏ចាប់បំបែកគ្នារៀងៗខ្លួន ។ លុះព្រឹកឡើងឈ្មោះ **ស ឌ** ត្រូវបានសមត្ថកិច្ចបញ្ជូនខ្លួនមកតុលាការតែម្តង ឯឈ្មោះ **ឧ សម** ក៏បានគេចខ្លួនរហូតមកដល់សព្វថ្ងៃ ។

**<u>នាពេលសវនាការ</u>**

-ឈ្មោះ **ស ឌ** ហៅ ៥ ជាជនជាប់ចោទបានឆ្លើយថា កាលពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៣ វេលាម៉ោង ០៦ និង ៣០នាទីឈ្មោះ **ឧ សម** បានខឹងនឹងកូនប្រុសគាត់ឈ្មោះ **ឧ ឌ** យ៉ាងខ្លាំង ហើយបានលីកាំបិតផ្គាក់ដើរកាត់មុខផ្ទះរបស់ខ្លួន ដោយស្រែកឡូឡាថា : អញកាប់ហ្អែងអោយងាប់ ហើយយកខ្លួនប្រពន្ធហ្អែងទៀត ។ ដោយឮដូច្នោះប្រពន្ធខ្លួនបានស្រែកអោយគាត់វិញថា កាប់កូនពូឯងងាប់ទៅម្តេចក៏មើលងាយប្អូនថ្លៃខ្លួនទៀត គ្រាន់តែនិយាយប៉ុណ្ណឹងឈ្មោះ **ឧ សម** បានស្ទុះមកបោចសក់ប្រពន្ធខ្លួនដួលទៅដី ហើយកាប់ខ្លួន ០១កាំបិតចំស្មាស្តាំ ដោយខឹងពេកខ្លួនក៏រត់ទៅផ្ទះយកកាំបិតផ្គាក់មកដល់ពាក់កណ្តាលផ្លូវ ស្រាប់តែឈ្មោះ **ឧ សម** បានពួននៅគុម្ពស្មៅក្បែរនោះស្ទាក់វាយខ្លួនមួយដំបងចំគុម្ពត្រចៀកបណ្តាលអោយដួលផ្កាប់មុខ បន្ទាប់មកប្រពន្ធរបស់ឈ្មោះ **ឧ សម** បានកាប់ខ្លួនមួយកាំបិតប៉ុងតោចំកដៃមួយកាំបិតទៀត ពេលនោះអ្នកជិតខាងបានរត់មកជួយឃាត់ បន្ទាប់មកខ្លួនបានក្រោកឡើងទាញកាំបិតកាប់ទៅចំជើងរបស់ **ឧ សម** មួយកាំបិតរួចហើយទើបអ្នកជិតខាងចាប់បំបែកគ្នាទៅ ។ លុះព្រឹកឡើងសមត្ថកិច្ចបានឃាត់ខ្លួន ហើយបញ្ជូនមកតុលាការឃុំខ្លួននៅពន្ធនាគាររហូតដល់សព្វថ្ងៃនេះ ។ ក្នុងរឿងនេះខ្លួនសុំអោយតុលាការជួយបន្ធូរបន្ថយទោសអោយខ្លួនផង ។ ចំណែកឈ្មោះ **ឧ សម** ក្រោយពេលសមត្ថកិច្ចសួរនាំរួចហើយក៏រត់គេចខ្លួនបាត់រហូតដល់សព្វថ្ងៃនេះទាំងក្រុមគ្រួសារ ។

-តាមការអានចម្លើយរបស់ឈ្មោះ **ឧ សម** ហៅ ញ ជាជនរងគ្រោះបានឆ្លើយថា : កាលពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៣ ឈ្មោះ **ស ឌ** ហៅ ៥ បានផឹកស្រាស្រវឹង ព្រមទាំងបានមករករឿងខ្លួនដោយនិយាយថា : បើហ៊ានតែប៉ះប្អូនស្រីវ៉ា "ត្រូវជាកូនប្រសាររបស់ខ្លួន" តែបន្តិចក៏វ៉ាមិនទុកជីវិតអោយរស់ដែរ ហើយខ្លួនបានតបទៅវិញថា "អញមិនប៉ះពាល់អ្វីប្អូនឯងទេ អញនិយាយតែកូនអញទេ" បន្ទាប់មក **ស ឌ** ក៏ចេញទៅបាត់បន្ទាប់មកវ៉ាក៏ត្រឡប់មកវិញដោយកាន់កាំបិតផ្គាក់ ហើយកាប់ខ្លួនចំជើងឆ្វេងបណ្តាលអោយបាក់ឆ្អឹងដួលនៅនឹងកន្លែង ដោយឃើញដូច្នោះប្រពន្ធខ្លួនបានគប់ឈ្មោះ **ស ឌ** មួយកាំបិតប៉ុងតោចំក្រោមដៃស្តាំបណ្តាលអោយរងរបួសដែរ ក្នុងរឿងនេះខ្លួនសំណូមពរសុំ

CamScanner

អោយតុលាការជួយរកយុត្តិធម៌អោយខ្លួន និង ធ្វើការផ្តន្ទាទោសលើឈ្មោះ **ស ឆ** តាមច្បាប់ ។

-ឈ្មោះ **ស ន** ហៅ **ញ** ជាសាក្សីបានឆ្លើយថា : កាលពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៣ វេលាម៉ោង ៧:០០ ជិត ៨:០០យប់ឈ្មោះ **ខ ញ** ហៅ **ឆ សប** បាននិយាយថា អញចុយក្តិតប្រពន្ធអា ឆ ម្តងមើល និង ចង់កាប់កូនចោល ទៀត ។ នៅពេលនោះខ្លួនបានសួរទៅចង់កាប់កូន កាប់កូនទៅ ហេតុអ្វីបានជាពួឯងចង់ចុយកូនប្រសារទៀតឈ្មោះ **ខ ញ** ឆ្លើយថា បើហ្អែងចេះអញចុយទាំងបងទាំងប្អូនទៀត ។ ពេលនោះប្តីខ្លួនឈ្មោះ **ស ឆ** ឆ្លើយថា : ពួឯងកាប់ៗទៅ កុំអោយប៉ះពាល់ដល់ប្អូនស្រីខ្លួន ពេលនោះឈ្មោះ **ខ ញ** ក៏ស្ទុះទៅបំរុងកាប់ប្តីរបស់ខ្លួន តែខ្លួនឃាត់ ហើយឈ្មោះ **ខ ញ** បានចាប់បោចសក់ខ្លួនផ្ទប់ទៅដីឃើញដូច្នោះ ប្តីខ្លួន **ស ឆ** បានស្ទុះទៅជួយតែត្រូវឈ្មោះ **ញ** កាប់មួយកាំបិតផ្គាក់ចំស្មាពេលនោះប្តីខ្លួនបានរត់ទៅផ្ទះយកកាំបិតផ្គាក់មកដែរ ពេលមកដល់ពាក់កណ្តាលផ្លូវត្រូវឈ្មោះ **ញ** ស្ទាក់វាយគាត់មួយដំបងចំគុម្ពត្រចៀកបណ្តាលអោយដួល ហើយប្តីខ្លួនបានងើបឡើង ហើយកាប់សងទៅលើឈ្មោះ **ញ** មួយកាំបិតចំជើងឆ្វេង បន្ទាប់មកប្រពន្ធរបស់ឈ្មោះ **ញ** បានកាប់ប្តីខ្លួនមួយកាំបិតប៉ុងតោចំដៃស្តាំ ហើយរត់ចូលផ្ទះបាត់ទៅ ។

លុះស្អែកឡើងប្តីខ្លួនត្រូវសមត្ថកិច្ចឃាត់ខ្លួនបញ្ជូនមកតុលាការ ធ្វើការឃុំខ្លួននៅពន្ធនាគាររហូតដល់សព្វថ្ងៃនេះ ។ ក្រោយមកឈ្មោះ **ឆ សប** ហៅ **ញ** ក៏រត់គេចខ្លួនបាត់រហូតមិនដឹងទៅរស់នៅឯណាទៅទាំងក្រុមគ្រួសារ ។

-តាមការអានចម្លើយរបស់ឈ្មោះ **ត តស** ជាសាក្សីបានឆ្លើយថា : នៅព្រឹកក្រោយថ្ងៃកើតហេតុថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៣ យប់ប្រជាពលរដ្ឋបានរាយការណ៍ប្រាប់ប៉ុស្តិ៍នគរបាលសង្កាត់អូរត្រេះ ពេលនោះប៉ូលិសបានហៅឈ្មោះ **ស ឆ** មកសាកសួរ ហើយ **ស ឆ** បានឆ្លើយសារភាពថា ខ្លួនពិតជាបានកាប់ឈ្មោះ **ខ ញ** មួយកាំបិតផ្គាក់ដោយមូលហេតុឈ្មោះ **ខ ញ** បានកាប់គាត់មុន ។

-បានឃើញលិខិតបញ្ជាក់ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៤ របស់ចៅសង្កាត់អូរត្រេះ ឈ្មោះ **ខ ញ** (**ឆ សប**) និង ឈ្មោះ **ស ញ** មានទីលំនៅក្រុមទី ៤ សង្កាត់អូរត្រេះ ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ បានចាកចេញពីភូមិមិនដឹងទៅរស់នៅឯណា ដោយមិនបានជំរាបអោយអាជ្ញាធរដឹងទេ ។

-តំណាងអយ្យការបានធ្វើការសន្និដ្ឋានទោសថា : មានពិរុទ្ធភាពលើឈ្មោះ **ស ឆ** ហៅ **ជ** ពីបទបង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិ ៤ សង្កាត់អូរត្រេះ ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៣ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនជាប់ចោទឈ្មោះ **ស ឆ** បានឆ្លើយសំដីចុងក្រោយបង្អស់ថា ខ្លួនសុំអោយតុលាការជួយបន្ធូរបន្ថយទោសខ្លួនឈប់ប្រព្រឹត្តអំពើបែបនេះទៀតហើយ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ការអានចម្លើយដើមបណ្តឹង

-ក្រោយពីបានស្តាប់ការអានចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

**<u>តុលាការក្រុងព្រះសីហនុ</u>**

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>យល់ឃើញថា</u>**

កាលពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៣ វេលាម៉ោង ០៦ និង ៣០នាទីយប់ ពិតជាមានករណីបង្ករបួសដោយ

CamScanner

ចេតនា ប្រព្រឹត្តនៅភូមិ ៤ សង្កាត់អូរត្រេះ ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ប្រាកដមែនរវាងឈ្មោះ ខ សម និង ស ធ គឺកាប់ទៅកាប់មកបណ្តាលអោយមានរបួសរៀង១ខ្លួនឈ្មោះ ស ធ ត្រូវសមត្ថកិច្ចចាប់ខ្លួន ឯឈ្មោះ ខ សម ក្រោយសមត្ថកិច្ចសួរចម្លើយរួចហើយ ក៏គេចខ្លួនបាត់រហូតដល់សព្វថ្ងៃ ។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ ស ធ បានបញ្ជាក់ថា : ខ្លួនពិតជាបានកាប់ទៅលើឈ្មោះ ខ ញ បណ្តាលអោយរបួសត្រង់ជើងប្រាកដមែន អំពើនេះបណ្តាលមកពីឈ្មោះ ខ ញ និយាយប្រមាថមើលងាយប្អូនស្រីរបស់ខ្លួន ហើយព្រមទាំងកាប់មកលើខ្លួនបណ្តាលអោយរងរបួសមុន ទើបខ្លួនទ្រាំមិនបាន ។ តែឈ្មោះ ខ ញ ហៅ ខ សម បានកាប់ខ្លួនចំនួន ០២កាំបិតមួយកន្លែងត្រូវស្មា និង មួយកន្លែងទៀតត្រូវដៃ និង ត្រូវមួយដំបងទៀតត្រូវចំពុះត្រចៀក សមត្ថកិច្ចមិនបានចាប់ខ្លួនឈ្មោះ ខ សម ទេទុកអោយ ខ សម រត់គេចខ្លួនបាត់ ។

-តាមចម្លើយសាក្សីឈ្មោះ ស ន ជាប្រពន្ធរបស់ឈ្មោះ ស ធ ឆ្លើយថា : ប្តីខ្លួនពិតជាបានកាប់ទៅលើឈ្មោះ ខ ញ មួយកាំបិតចំជើងបណ្តាលអោយរងរបួស កាលពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៣ ប្រាកដមែន ដោយហេតុមកពីឈ្មោះ ញ បាននិយាយមើលងាយប្អូនថ្លៃខ្លួន និង ព្រមទាំងបានកាប់ទៅលើប្តីខ្លួនអោយរងរបួសមុន ។

-តាមចម្លើយសាក្សីឈ្មោះ ត តស បានឆ្លើយថា : ឈ្មោះ ស ធ បានឆ្លើយសារភាពថា ខ្លួនពិតជាបានបង្ករបួសស្នាមទៅលើឈ្មោះ ញ ដោយឈ្មោះ ញ បានបង្ករបួសមកលើខ្លួនគាត់មុនកាលពីយប់ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៣ ទើបខ្លួនគាត់ធ្វើដូច្នេះ ។

-ការប្រព្រឹត្តរបស់ជនជាប់ចោទ ដោយទ្រាំពុំបាននឹងទង្វើរបស់ជនរងគ្រោះ ខ្វះការពិចារណា ហើយជនជាប់ចោទមានកិរិតវប្បធម៌ទាប ម្យ៉ាងទៀតជនជាប់ចោទ ទើបតែប្រព្រឹត្តបទល្មើសដំបូង ។ ម្យ៉ាងទៀតជនរងគ្រោះក៏បានប្រព្រឹត្តបទល្មើសទៅលើឈ្មោះ ស ធ ចំនួន ០២កាំបិត និង វាយមួយដំបងផងដែរ ចំណុចនេះតំណាងអយ្យការមិនបានធ្វើការចោទប្រកាន់លើឈ្មោះ ខ សម ទេ ធ្វើការចោទប្រកាន់តែឈ្មោះ ស ធ ម្នាក់តែប៉ុណ្ណោះ ហើយ ស ធ ក៏ជាជនរងគ្រោះផងដែរនៅក្នុងរឿងនេះ ។

-អំពើល្មើសរបស់ជនជាប់ចោទបំពានលើមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ហើយក៏បានធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និង សុខភាពរបស់អ្នកដទៃទៀតផង ។

-មានពិរុទ្ធភាពលើឈ្មោះ ស ធ ហៅ ៩ ពីបទបង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិ ៤ សង្កាត់អូរត្រេះ ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៣ ។

## ហេតុដូច្នេះតុលាការក្រុងព្រះសីហនុ

## សំរេច :

ផ្តន្ទាទោសឈ្មោះ ស ធ ហៅ ៩ ភេទប្រុស អាយុ ៣៩ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៦ខែ ( ប្រាំមួយខែ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៣ និង ទោសព្យួរ ០៨ខែ មានរយៈពេលសាកល្បង ០៥ឆ្នាំ គិតចាប់ពីថ្ងៃនេះតទៅ ។

ពីបទបង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិ ៤ សង្កាត់អូរត្រេះ ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៣ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤១ និង ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ បើកផ្លូវ

CamScanner

ប្ដឹងទាស់ និង ប្ដឹងឧទ្ធរណ៍ក្នុងអំឡុងច្បាប់ ។

ក្រឡាបញ្ជី

[redacted]

ចៅក្រមជំនុំជំរះ

[redacted]

CamScanner